**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ០១ សសរ

# សេចក្ដីសម្រេច
## ស្ដីពី
## ការតែងតាំងសមាសភាពគណៈកម្មការអន្តរក្រសួង សម្រាប់រៀបចំប្រារព្ធទិវាវប្បធម៌ជាតិ ៣ មីនា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២/ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០០៦ ស្ដីពីការបង្កើតទិវាវប្បធម៌ជាតិ
- បានឃើញអនុក្រឹត្យលេខ ២៤ អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៧ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

## សម្រេច

**ប្រការ១ .-**

ត្រូវបានតែងតាំងសមាសភាពគណៈកម្មការអន្តរក្រសួងសម្រាប់រៀបចំប្រារព្ធទិវាវប្បធម៌ជាតិ ៣មីនា ដែលមានសមាសភាពដូចខាងក្រោម៖

| | | | | | |
|---|---|---|---|---|---|
| ១- | លោកជំទាវ | **ភឿង សកុណា** | រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ | ប្រធាន |
| ២- | ឯកឧត្តម | **ច័ន្ទ តានី** | រដ្ឋលេខាធិការទីស្ដីការគណៈរដ្ឋមន្ត្រី | អនុប្រធាន |
| ៣- | ឯកឧត្តម | **ឈិន កេតនា** | អនុប្រធានអចិន្ត្រៃយ៍ និងជាអគ្គលេខាធិការនៃគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ | អនុប្រធាន |
| ៤- | ឯកឧត្តម | **ឈន សុភាព** | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | អនុប្រធាន |
| ៥- | ឯកឧត្តម | **គេង សាវឌ្យ** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ៦- | លោកជំទាវ | **ដាំ ដារីនី** | រដ្ឋលេខាធិការក្រសួងការពារជាតិ | សមាជិកា |
| ៧- | ឯកឧត្តម | **ញាណ ភឿន** | រដ្ឋលេខាធិការក្រសួងធម្មការនិងសាសនា | សមាជិក |
| ៨- | ឯកឧត្តម | **ជា ច័ន្ទបរិបូរណ៍** | រដ្ឋលេខាធិការក្រសួងព័ត៌មាន | សមាជិក |
| ៩- | លោកជំទាវ | **ចម និម្មល** | រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | សមាជិកា |

| | | | | |
|---|---|---|---|---|
| ១០- ឯកឧត្តម | **ប៉ាន់ សុខុម** | | រដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| ១១- លោកជំទាវ | **ឃឹម ចំរើន** | | រដ្ឋលេខាធិការក្រសួងកិច្ចការនារី | សមាជិកា |
| ១២- លោកជំទាវ | **ឃុន រចនា** | | អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | សមាជិកា |
| ១៣- ឯកឧត្តម | **តាន់ ឌុដ្ឋា** | | ទីប្រឹក្សាក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ១៤- ឯកឧត្តម លោកជំទាវ តំណាងអភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត | | | | សមាជិក។ |

**ប្រការ២ ._**

គណៈកម្មការនេះ មានភារកិច្ចដូចខាងក្រោម៖

- ធ្វើសារាចរណែនាំស្តីពីការរៀបចំប្រារព្ធ «ទិវាវប្បធម៌ជាតិ ៣មីនា»
- រៀបចំប្រធានបទ ខ្លឹមសារ រូបភាពបម្រើឲ្យ «ទិវាវប្បធម៌ជាតិ» ក្នុងឆ្នាំនីមួយៗ
- បំផុសនិងអំពាវនាវគ្រប់មជ្ឈដ្ឋាន និងសប្បុរសជន ដើម្បីជួយឧបត្ថម្ភគាំទ្រ «ទិវាវប្បធម៌ជាតិ»
- ទទួលភារកិច្ចផ្សេងៗទៀត ដែលរាជរដ្ឋាភិបាលប្រគល់ជូន។

**ប្រការ៣ ._**

គណៈកម្មការនេះ ត្រូវបង្កើតលេខាធិការដ្ឋានអចិន្ត្រៃយ៍មួយ ដែលមានទីតាំងនៅទីស្តីការក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ដើម្បីចាត់ចែងការងារប្រចាំថ្ងៃ និងអាចបង្កើតអនុគណៈកម្មការមួយចំនួនតាមការចាំបាច់ ដែលអនុគណៈកម្មការនីមួយៗត្រូវដឹកនាំដោយប្រធាន០១ (មួយ) រូប។

គណៈកម្មការនេះ មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ដើម្បីសម្រួលដល់ដំណើរការការងាររបស់ខ្លួន។

**ប្រការ៤ ._**

អនុប្រធាន និងសមាជិកនៃគណៈកម្មការនេះ និងប្រធាន និងសមាជិកនៃអនុគណៈកម្មការ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។

**ប្រការ៥ ._**

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវជួយសម្របសម្រួលថវិកាជូនគណៈកម្មការនេះ តាមតម្រូវការជាក់ស្តែង។

**ប្រការ៦ ._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៧ ._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ប្រធានគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ៕

ថ្ងៃ ព្រហ ១១ កើត ខែ បុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែមករា ឆ្នាំ២០១៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៧
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ